# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៥ សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យសពឯកឧត្តម ថ្លាង តាន់ អភិបាលខេត្តព្រះវិហារ ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យសព ឯកឧត្តម ថ្លាង តាន់ អភិបាលខេត្តព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **មិន ឃិន** | រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា | ប្រធាន |
| ២-ឯកឧត្តម **ជា សាន** | អនុប្រធានបុណ្យជាតិ និងជាអគ្គលេខាធិការរងទី១ | អនុប្រធាន |
| ៣-ឯកឧត្តម **ចក់ ឡេង** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥-ឯកឧត្តម **កែប ជុតិមា** | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៦- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៧- តំណាង ក្រសួងការពារជាតិ | | សមាជិក |
| ៨- តំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |

១២- តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៣- តំណាង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

- រួមសហការជាមួយក្រសួង ស្ថាប័ននានា និងក្រុមគ្រួសារសព ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណីជាតិឱ្យប្រព្រឹត្តទៅបានល្អប្រសើរ
- ពិនិត្យ និងលើកសំណើដោះស្រាយរាល់ការលំបាកនានា ទាក់ទិងនឹងការរៀបចំបុណ្យសព
- ណែនាំ និងបង្កលក្ខណៈងាយស្រួលដល់គណៈកម្មការរៀបចំពិធីបុណ្យរបស់ក្រសួងមហាផ្ទៃ ដោយអនុវត្តបានល្អប្រសើរតាមភារកិច្ចរៀង១ខ្លួន
- រៀបចំឱ្យមានកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីបុណ្យសព និងពេលដង្ហែសពឱ្យបានល្អប្រសើរ
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវ ដែលបានអញ្ជើញចូលរួមក្នុងពិធីបុណ្យសពនិងគោរពវិញ្ញាណក្ខ័ន្ធ
- លើកគម្រោង និងចាត់ចែងរាល់ការចំណាយសម្រាប់បម្រើឱ្យពិធីបុណ្យសព
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឱ្យពិធីបុណ្យ ។

**ប្រការ ៣ :** ថវិកាចំណាយសម្រាប់ការរៀបចំពិធីបុណ្យសព ជាបន្ទុកថវិការបស់រដ្ឋ ។

**ប្រការ ៤ :** គណៈកម្មការ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារបន្ថែម ជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមាករចាំបាច់ ដើម្បីធានាឱ្យការរៀបចំបុណ្យសព ប្រព្រឹត្តទៅតាមប្រពៃណីបានល្អប្រសើរ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
ចប្រការ ៥ " ដើម្បីអនុវត្ត
កសារ-កាលប្បវត្តិ

www.pheakdeylaw.com